## **អតិបូជាចារ្យមិនសំណាក់ធម៌បុគ្គលិកអង្គការការីតាសកម្ពុជា**

## **ពីព្រះសហគមន៍តាកែវ**

## **បាត់ដំបង ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២**

## **"បេសកកម្មរបស់យើងគឺបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់"**

**អត្ថបទទី១៖ យ៉ាកុប ២,១-៩**

ព្រះជាម្ចាស់បានជ្រើសរើសអ្នកក្រក្នុងលោកនេះ ឲ្យទៅជាអ្នកមានផ្នែកខាងជំនឿ យក ២,៥

**ដំណឹងល្អ៖ ម៉ាកុស ៨,២៧-៣៣**

គំនិតអ្នកមិនមែនជាគំនិតរបស់ព្រះជាម្ចាស់ទេ។ មក ៨,៣៣

បងប្អូនជាទីស្រឡាញ់

អ្នកដែលធ្វើការនៅក្នុងអង្គការការីតាស ដូចជាជីវិតរបស់យើងជាគ្រីស្តបរិស័ទតែម្តង។ លោកយ៉ាកុប បានសរសេរអត្ថបទនេះ២០០០ឆ្នាំមុន នៅពេលយើងស្តាប់អត្ថបទនេះ តាមពិតមិនខុសពីអ្វីដែលបានកើតឡើងនៅក្នុងសង្គមបច្ចុប្បន្ននេះ។ នៅពេលនោះ មានពិធីជប់លៀង នៅក្នុងពិធីជប់លៀងនេះមានបុរសម្នាក់ដែលចូលទៅជាអ្នកមានមែនទែន។ គាត់មានចិញ្ចៀន គាត់មានខ្សែកមាសធំៗ គាត់មានសម្លៀកបំពាក់ស្អាតៗ ពេលគាត់មកដល់ភ្លាមគេមកស្វាគមន៍ គេឱ្យកន្លែងអង្គុយនៅកៅអីកិត្តិយស ដើម្បីឱ្យគាត់ស្រួល។ ដោយបានរៀបចំទឹកត្រជាក់ៗ មានម្ហូបអាហារឆ្ងាញ់បំផុត ដែលមានគ្រប់មុខឱ្យគាត់បរិភោគ។ ប៉ុន្តែ នៅពេលនោះក៏មានអ្នកក្រីក្រម្នាក់ដែលចូលដែរ អ្នកក្រីក្រនេះគាត់អត់មានសម្លៀកបំពាក់ស្អាតសោះ និងមានក្លិនមិនល្អទៀត។ ដោយសារគាត់អត់បានមុជទឹកពីរបីថ្ងៃហើយ ដូច្នេះពេលគេឃើញគាត់គេឱ្យគាត់ទៅកៀន ទៅឱ្យឆ្ងាយ ឱ្យគាត់អង្គុយលើកន្ទេលនៅឆ្ងាយពីគេ និងឱ្យម្ហូបដែលនៅសល់ពីតុអ្នកមាន។

តាមពិត ខ្ញុំគិតថានេះជាធម្មជាតិរបស់មនុស្សយើងដែរ យើងចូលចិត្តគោរពពេលមានអ្នកធំមកដល់ យើងគោរពគាត់ យើងមើលថែរក្សាគាត់។ អ្នកផ្សេងៗយើងមើលឃើញដែរ ប៉ុន្តែយើងបណ្តេញគេ យើងមិនចាប់អារម្មណ៍ពីគេ។ នៅត្រង់នេះ បានណែនាំឱ្យយើងយល់ថា យើងមិន

អាចវិនិច្ឆ័យមនុស្ស យើងមិនអាចនិយាយថាមនុស្សនេះជាមនុស្សល្អ ឬជាមនុស្សអាក្រក់។ មនុស្សនេះជាអ្នកមាន ដូច្នេះគាត់ពោរពេញដោយអំណោយទាន យើងត្រូវតែបម្រើគាត់ មនុស្សនេះជាអ្នកក្រីក្រ ដូច្នេះយើងត្រូវការបណ្តេញគាត់ ដោយសារគាត់អត់មានប្រយោជន៍។ ជួនកាលនៅពេលយើងជ្រើសរើសមិត្តភក្តិរបស់យើង យើងជ្រើសរើសមិត្តភក្តិដែលអាចផ្តល់ផលប្រយោជន៍សម្រាប់យើងនៅពេលក្រោយ។ យើងជ្រើសរើសទំនាក់ទំនងជាមួយមនុស្សដែលយើងដឹងថា នៅថ្ងៃអនាគតអាចទៅជាខ្សែមួយប្លែក ខ្ញុំអាចពឹងពាក់គេបាន ដូច្នេះយើងចេះនិយាយផ្អែមជាមួយគេ។ សម្រាប់អ្នកដែលគ្មានប្រយោជន៍សម្រាប់យើងនៅពេលក្រោយ យើងចេះតែមើលគេពីចម្ងាយ និងអត់សូវរវីរវល់ជាមួយគេសោះ។

ប៉ុន្តែ តាមពិតអ្វីដែលយើងស្តាប់ថ្ងៃនេះ គឺជាអ្នកក្រីក្រដែលនឹងទទួលព្រះរាជដែលព្រះជាម្ចាស់មានព្រះបន្ទូលសន្យា។ ប្រសិនបើ ចាំអ្វីដែលយើងបាននិយាយនៅក្នុងថ្ងៃនេះ បេសកកម្មរបស់យើង គឺណែនាំឱ្យព្រះរាជរបស់ព្រះជាម្ចាស់ឆាប់កើតឡើងនៅលើផែនដីនេះ។ មានន័យថាណែនាំឱ្យមនុស្សទាំងអស់អាចរកឃើញសេចក្តីសុខសុភមង្គល ឱ្យមានសេចក្តីសង្ឃឹម ឱ្យមានជីវិត ដោយដឹងថាជីវិតរបស់គេមានតម្លៃថ្លៃថ្នូរ។ ហេតុនេះហើយ ការងាររបស់យើងពិតមែនគឺធ្វើដូចម្តេចដើម្បីឱ្យអ្នកតូចតាចអាចរកឃើញសេចក្តីសុខ អ្នកតូចតាចអាចយល់ថាគេមានជីវិត គេមានតម្លៃដ៏ពិតប្រាកដមែន។ មិនវិនិច្ឆ័យគេ ដោយសារយើងឃើញរបៀបរស់នៅរបស់គាត់ខុសពីគេ ផ្ទុយទៅវិញយើងណែនាំឱ្យគាត់ចូលបន្តិចម្តងៗ នៅក្នុងសង្គមដើម្បីឱ្យគាត់មានជីវិតរបស់គាត់ផ្ទាល់ខ្លួន សេចក្តីសុខ និងតម្លៃថ្លៃថ្នូររបស់គាត់ផ្ទាល់ខ្លួនដែរ។ ដោយសារ តាមពិតដូចព្រះយេស៊ូបានបង្រៀនយើង ឱ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង។ ពីសម័យដើម នៅក្នុងសម្ពន្ធមេត្រីចាស់ នៅក្នុងធម៌វិន័យ យើងបានស្តាប់ដែរ "**ត្រូវស្រឡាញ់បងប្អូនឯទៀតៗឱ្យបានដូចស្រឡាញ់ខ្លួនឯង**"។ ដូច្នេះ ឱ្យយើងចាំនេះ យើងជាការីតាសមានន័យថា យើងជាធម៌មេត្តាករុណា និងធម៌មេត្តាករុណាមានប្រភពមួយ គឺព្រះជាម្ចាស់ផ្ទាល់។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ដែលបានណែនាំយើង ដើម្បីឱ្យយើងរស់នៅក្នុងសេចក្តីសុខក្នុងជីវិតរបស់យើង។ អរព្រះគុណព្រះជាម្ចាស់ ដែលបានផ្តល់កម្លាំងដើម្បីឱ្យយើងទៅមុខតទៅទៀតនៅក្នុងបេសកកម្មរបស់យើង។ ដោយដឹងថា មនុស្សទាំងអស់មានតម្លៃស្មើៗគ្នា មនុស្សទាំងអស់ចង់មានកម្លាំងកាយកម្លាំងចិត្តដូចៗគ្នា។ តួនាទីរបស់យើង គឺណែនាំឱ្យមនុស្សដែលគេភ្លេច គេមើលមិនឃើញនៅក្នុងពិធីជប់លៀង ឱ្យគេមានមោទនភាព ដើម្បីឱ្យគេមានកិត្តិយស ឱ្យ

គេមានកម្លាំងថ្មី ដើម្បីអង្គុយរួមតុជាមួយយើង ហូបបាយជាមួយយើង និងរកឃើញជីវិតដែលជាជីវិតដ៏ពេញលក្ខណៈ៕

+ លោកអភិបាល អូលីវីយេ៉ ថ្មីតហាស្លេ
អភិបាលព្រះសហាគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/Bg2uKpEbSKE